
ការអភិវឌ្ឍធនធានរ៉ែនៅប្រទេសឡាវ
Eravanh Boungnaphalom
នាយកផ្នែកអធិការកិច្ចបរិស្ថាន និងអាជីវកម្មរ៉ែ នៃនាយកដ្ឋានរ៉ែ
ក្រសួងថាមពល និងរ៉ែ
សន្និសិទអន្តរជាតិ “ឱកាសសម្រាប់កម្ពុជា”
ថ្ងៃទី 26-27 ខែឧសភា ឆ្នាំ 2010, ភ្នំពេញ

# មាតិកានៃបទបង្ហាញ

- ស្ថានភាពអាជីវកម្មរ៉ែសព្វថ្ងៃនេះនៅប្រទេសឡាវ
  - សក្តានុពលនៃធនធានរ៉ែ
  - គោលនយោបាយ និងបទប្បញ្ញត្តិនានាស្តីពីរ៉ែ
    - ការអភិវឌ្ឍដោយចីរភាព
  - ការវិនិយោគលើអាជីវកម្មរ៉ែ
- ភាពចាំបាច់ឱ្យមានកិច្ចការពារបរិស្ថាន
  - កិច្ចការពារបរិស្ថាន និងសង្គម
  - បញ្ហាបរិស្ថានដែលកើតមានជាទូទៅ
- សេចក្តីសន្និដ្ឋាន

# ស្ថានភាពអាជីវកម្មរ៉ែសព្វថ្ងៃនេះនៅប្រទេសឡាវ





ឡាវ ជាប្រទេសមួយដែលសំបូរធនធានរ៉ែ មានសក្តានុពលខ្ពស់សម្រាប់ការរកឃើញកំណប់រ៉ែថ្មីៗ និងការអភិវឌ្ឍកំណប់រ៉ែទាំងនោះដោយជោគជ័យ ជាឧស្សាហកម្មរ៉ែខ្នាតមធ្យម និងខ្នាតធំ

- គម្រោងយករ៉ែមាស និងទង់ដែងនៅតំបន់សេប៉ុន (ដោយក្រុមហ៊ុន Lane Xang Minerals Ltd ដែលគេស្គាល់ថាជា MMG) គឺជាគំរូល្អមួយ អំពីជោគជ័យក្នុងចំណោមគម្រោងនិមិត្តរូបមួយចំនួនតូច ដែលបានចាប់ផ្តើមប្រតិបត្តិការនៅក្នុងឆ្នាំ 2003; ក្រុមហ៊ុន Phu Bia Mining Ltd បានចាប់ផ្តើមប្រតិបត្តិការនៅក្នុងឆ្នាំ 2005

- វិស័យរ៉ែ រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងកាត់បន្ថយភាពក្រីក្រ។ ក្នុងរយៈពេល 6 ចុងក្រោយនៃឆ្នាំ 2009-2010 ផលចំណូលពីវិស័យរ៉ែ បានកើនឡើង 38,99% ធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំទៅ។ តំបន់សេប៉ុនផលិតមាសបាន 1.761 គក កាតូតទង់ដែង 34.772 តោន ។ ក្រុមហ៊ុន Phu Bia mining Ltd បានផលិតមាស 496 គក និង ទង់ដែងចម្រាញ់ហើយ 150.771 តោន។

- គេបានព្យាករណ៍ថា ការនាំចេញផលិតផលរ៉ែ នៅក្នុងឆ្នាំ 2009 បានកើនដល់ 85% នៃការនាំចេញសរុបរបស់ប្រទេសឡាវ និងរួមចំណែក 18% នៃផលិតផលក្នុងស្រុកសរុប ហើយតួលេខនេះនឹងកើនឡើងជាបន្ថែមទៀត។

# សក្តានុពលនៃធនធានរ៉ែ




Source: DGM/10/2003

- ចំនួនសរុបនៃកំណប់រ៉ែ និងការរំពឹងទុក គឺមាន 511 កន្លែង ក្នុងនោះ រ៉ែមាស 150 កន្លែង ទង់ដែង 45 កន្លែង សង្កសី និងសំណ 75 កន្លែង សំណប៉ាហាំង 45 កន្លែង រ៉ែដែក 52 កន្លែង លោហធាតុផ្សេងទៀត 36 កន្លែង ហ្សីបសូម 6 កន្លែង ថ្មកំបោរ 9 កន្លែង ថ្មអំបិល 36 កន្លែង និងរ៉ែផ្សេងៗទៀតសម្រាប់ឧស្សាហកម្ម 14 កន្លែង ធ្យូងថ្ម 37 កន្លែង និងត្បូងថ្មមានតម្លៃ 6 ។

- កំណប់រ៉ែមាស មាន 32 លានតោន មាសរលាយ 12 លានតោន ទង់ដែង 162 លានតោន សង្កសី 0,09 លានតោន សំណប៉ាហាំង 38 លានតោន រ៉ែដែក 26 លានតោន ហ្សីបសាម 8 លានតោន សារធាតុជីឥដ្ឋ 5 តោន ខ្សាច់កញ្ចក់ 4 លានតោន ថ្មកំបោរ 14 លានតោន បារីត 0.01 លានតោន ហ្វូស្វរីត 0.01 លានតោន ធ្យូងថ្ម 7 លានតោន។ល។

ចំពោះព័ត៌មានបន្ថែម សូមអានក្នុងវេបសាយ

http://www.dgm.gov.la